ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

បណ្ណបច្ចេកទេស ២០១៥/០១

# ជំងឺស្លឹកអូអ៊ីដ្យូមឬប្រផេះស

# Oidium Leaf disease



ការផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា
ការិយាល័យដាំដុះនិងការពារ

## ១. លក្ខណៈទូទៅ

ជំងឺស្លឹកអូអ៊ីដ្យូមឬប្រផេះស (*Oidium* leaf disease) អាចកើតមានក្នុងកម្រិតខុសៗគ្នានៅតំបន់ដាំកៅស៊ូ។ បញ្ហានេះបណ្តាលមកពីការជ្រុះស្លឹកយឺត ឬពន្យាពេលជ្រុះស្លឹករបស់ក្លូនកៅស៊ូ។ ភាពធ្ងន់ធ្ងរនៃជំងឺប្រែប្រួលទៅតាមរដូវជ្រុះស្លឹក អាយុស្លឹក ក្លូនងាយចម្លងជំងឺនិងលក្ខខណ្ឌអាកាសធាតុនៅពេលស្លឹកលាស់ឡើងវិញ។ ក្លូនកៅស៊ូដែលជ្រុះស្លឹកមុនដូចជា PB86 អាចគេចផុតពីជំងឺស្លឹកអូអ៊ីដ្យូម ឬប្រផេះស។ ជំងឺនេះរីករាលដាលដោយសារស្ព័រហើរតាមខ្យល់នឹងបង្កបញ្ហាខ្លាំងនៅតំបន់ខ្ពស់និងមានតិចតួចនៅតំបន់មានរយៈកំពស់ទាបជាង៩០ម៉ែត្រ។

## ២. រោគសញ្ញាជំងឺ

ជំងឺ *Oidium* leaf disease បង្កឡើងដោយផ្សិត *Oidium hevea* Stein។ ផ្សិតនេះបង្កើតស្ព័រមានលក្ខណៈជាម្សៅដែលមានមុខងារដូចប៉ារ៉ាស៊ីត (បញ្ញើក្អែក)។ កត្តាអាកាសធាតុមានសារសំខាន់ជាងគេដែលធ្វើឲ្យជំងឺវិវត្តទៅបាន។ កំដៅនិងសំណើមមានឥទ្ធិពលលើជីវិតរស់នៅ ការលូតលាស់ ការបំបែកស្ព័រនិងការចម្លងជំងឺនៃពពួកផ្សិត។ ពពួកផ្សិតរីកសាយភាយទៅគ្រប់ទិសទីដោយសារខ្យល់នាំទៅនូវពពួក Conidia ហើយការកកើតស្ព័រនិងការរាលដាលគឺទទួលឥទ្ធិពលពីអាកាសធាតុ ជាពិសេសសំណើមទាប កំដៅខ្ពស់ ជាទូទៅអាស្រ័យលើខ្យល់ក្ដួចខ្លាំងខណៈពេលដែលស្ព័រត្រូវរីកសាយភាយ។

ស្លឹកខ្ចីមានពណ៌ទង់ដែងនិងបៃតងភ្លាវ ជាតំណាក់កាលងាយទទួលរងជំងឺ។

រោគសញ្ញាលេចចេញជាស្នាមផ្ទាំងម្សៅពណ៌សលើផ្ទៃស្លឹកទាំងសងខាងនិងផ្ទៃក្រោមស្លឹកជិតទ្រនុង (Veins)។ ផ្សិតរាលដាលតភ្ជាប់ពីផ្ទាំងមួយទៅផ្ទាំងមួយទៀត ជួនកាលគ្របដណ្តប់លើផ្ទៃស្លឹកទាំងស្រុង។ នៅពេលស្លឹកខ្ចីកើតជំងឺវាក៏ស្វិតហើយជ្រុះ បន្សល់តែទងស្លឹកជាប់ដើម។ នៅពេលស្លឹកកំពុងលូតលាស់ទទួលរងនូវជំងឺ នឹងបណ្តាលឲ្យផ្ទៃនិងទម្រង់ស្លឹកប្រែប្រួលខុសធម្មតា ហើយស្លាកស្នាមនៃជំងឺជិតជាប់លើផ្ទៃស្លឹកមានពណ៌លឿងភ្លាវបន្សល់ទុកលើស្លឹកពេញមួយវដ្តជីវិត។





ស្លឹកខ្ចីដែលរងនូវជំងឺបានបង្ហាញយ៉ាងច្បាស់នូវស្នាមម្សៅពណ៌សលើស្លឹក ហើយស្នាមនេះចាប់ផ្តើមប្រែពណ៌ទៅជាពណ៌ត្នោតនិងក្លាយជាដំបៅរលួយ។ ការរាតត្បាតខ្លាំងរបស់ *Oidium* ធ្វើឲ្យស្លឹកជ្រុះច្រើននិងបុស្បុក (Canopies) មានសភាពអន់ថយ ហើយទិន្នផលធ្លាក់ចុះ។





ជំងឺ *Oidium* ធ្វើឲ្យការលូតលាស់របស់រុក្ខជាតិមានភាពយឺតយ៉ាវ ហើយការដុះសំបកថ្មីក៏យឺតផងដែរ។ នៅតំបន់មានរយៈកម្ពស់ខ្ពស់ការជ្រុះស្លឹកញឹកញាប់នាំមកនូវកង្វះអាហារបម្រុងទុកក្នុងដើមអាចបង្កឲ្យមានជំងឺ Dieback នៃមែកតូចធំដែលនាំឲ្យមានបរាសិតទីពីរកើតឡើងគឺ Bothryodiploidia theobromae Pat.។ *Oidium* hevea ធ្វើឲ្យផ្កាក្លាយជាពណ៌សហើយជ្រុះមុនពេញវ័យ ដែលបណ្តាលឲ្យផលិតកម្មគ្រាប់ថយចុះ។

## ៣. ការពារនិងព្យាបាល

បំប៉នជីអាសូតនិងប៉ូតាសនៅពេលកៅស៊ូរៀបនឹងចេញស្លឹកថ្មី

ដាំក្លូនធន់នឹងជំងឺដូចជា PR255, RRIC100, PB217,...

ព្យាបាលដោយម្សៅស្ពាន់ធ័រ៦-៩គីឡូក្រាមក្នុងមួយហិកតា

ទ្រីដេម័រ (Tridemorth) កម្រិត 0.02-0.04%

ស៊ូឡុក (Sulox 1%) កម្រិត ៤-៥គីឡូក្រាមក្នុងមួយហិកតា

នៅថ្នាលកូនប្រើឌីតាន (Dithane M45) កម្រិត ១%

ចំនួន២គីឡូក្រាមក្នុងមួយហិកតា

កាបិនដាស៊ីម (Carbendazim) កម្រិត 0.05%។




**វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា**

អាសយដ្ឋានៈ អគារលេខ ៩ មហាវិថី ប៉ែននុត (២៨៩) សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ឬ ប្រអប់សំបុត្រលេខ ១៣៣៧ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ/ទូរសារ : (៨៥៥) ២៣ ៨៨២ ៨៣១

សារអេឡិចត្រូនិច : crri@camnet.com.kh

វិបសាយ : www.crri.com.kh